ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៦២២
ចុះថ្ងៃទី ០៩.៧.១៣
សាលដីកា
លេខ :២១ក្រVI-ញ
ចុះថ្ងៃទី ២៥.៣.១៤

# តាមនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីដែលប្រកាសអោយប្រើតាមក្រឹត្យលេខ :០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភះ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៤ ដោយមានសមាសភាពចូលរួមដូចតទៅ :

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

អ្នកស្រី [redacted]

*ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍សំណុំរឿងព្រហ្មទណ្ឌចោទលេខ :៦២២ ចុះថ្ងៃទី ០៩ ខែ ៧ ឆ្នាំ ២០១៣ ដែលមាន :*

១. ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណវាសនា ភេទប្រុស អាយុ ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរ នាយកក្រុមហ៊ុន កើតនៅភូមិ ត្រាំង ឃុំ សៀមរាប ស្រុក សៀមរាប ខេត្ត សៀមរាប មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ: [redacted] ឪពុកឈ្មោះ: [redacted] "រ" ម្តាយឈ្មោះ: [redacted] "រ" ប្រពន្ធឈ្មោះ: [redacted] មានកូន ០៣ នាក់ ទោសពីមុនគ្មាន ។

- មានលោក [redacted] សុជល ជាមេធាវីការពារ

២. ជនជាប់ចោទឈ្មោះ: [redacted] ចាន់នី ហៅ ប៊ី លីចាន់ ភេទប្រុស អាយុ ៥១ឆ្នាំ ជាតិខ្មែរ មុខរបរ អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កើតនៅភូមិ ត្រពាំងបី ឃុំ បារាយណ៍ ស្រុក ព្រៃឈរ ខេត្ត កំពង់ចាម មានទីលំនៅសព្វថ្ងៃផ្ទះលេខ: [redacted] ឪពុកឈ្មោះ: [redacted] "ស" ម្តាយឈ្មោះ: [redacted] "ស" ប្រពន្ធឈ្មោះ: [redacted] មានកូន០៤នាក់ ទោសពីមុនគ្មាន ។

-មានលោក [redacted] ចំណាន ជាមេធាវីការពារ

ត្រូវចោទពីបទ :ឆបោក ប្រព្រឹត្តនៅរាជធានី ភ្នំពេញ កាលពីថ្ងៃទី ១៥ ខែ កក្កដា ឆ/.





Scanned with CamScanner

ឆ្នាំ ២០០៩ ។

*បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និង មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។*

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុមាលា ភេទស្រី អាយុ ៣០ឆ្នាំ មានទីលំនៅសព្វថ្ងៃផ្ទះលេខ: [redacted] ។

- មានលោកស្រី [redacted] ធនលាភី ជាមេធាវីតំណាង

តាមសេចក្តីសុំប្តឹងឧទ្ធរណ៍លេខ :៣៩៨ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ របស់ឈ្មោះ [redacted] សុវណ្ណវាសនា ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ : ៨៦(ឆ) ចុះថ្ងៃទី ២២ ខែ ៥ ឆ្នាំ ២០១៣ របស់សាលាដំបូងរាជធានី ភ្នំពេញ គ្រប់ចំណុចសេចក្តីសម្រេចទាំងមូល ។

តាមសេចក្តីសុំប្តឹងឧទ្ធរណ៍លេខ :៨០០ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ របស់លោក តៃ ចំណាន មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] ចាន់នី ហៅ ប៊ី លីចាន់ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ : ៨៦(ឆ) ចុះថ្ងៃទី ២២ ខែ ៥ ឆ្នាំ ២០១៣ របស់សាលាដំបូងរាជធានី ភ្នំពេញ គ្រប់ចំណុចទី១ នៃសេចក្តីសម្រេច ។

*ឯរឿងហេតុមានដូចតទៅ:*

កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩ ឈ្មោះ [redacted] សុវណ្ណវាសនា និង ឈ្មោះ [redacted] ស្រីម៉ាច ជាប្រពន្ធបានមកទទួលប្រាក់ថ្លៃលក់ដីពីឈ្មោះ [redacted] សុមាលា ចំនួន ២០០០០០ (ម្ភៃម៉ឺនដុល្លា) ហើយមិនមានដីដើម្បីធ្វើការផ្ទេរសិទ្ធិឲ្យមកឈ្មោះ [redacted] សុមាលា ឡើយ។ ការទិញលក់នេះឈ្មោះ [redacted] ចាន់នី ជាអ្នកធានាអះអាង ។ នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩ ឈ្មោះ [redacted] ចាន់នី បាននាំឈ្មោះ [redacted] សុវណ្ណវាសនា មកខ្ចីប្រាក់ពីឈ្មោះ [redacted] សុមាលា ចំនួន ១៨១០០០ (ដប់ប្រាំបីម៉ឺនមួយពាន់)ដុល្លាអាមេរិក ដែលប្រាក់នេះឈ្មោះ [redacted] ចាន់នី និង ឈ្មោះ [redacted] សុវណ្ណវាសនា បានផ្តិតមេដៃទទួលជាមួយគ្នា ហើយការខ្ចីនេះ ឈ្មោះ [redacted] ចាន់នី បានយកប្លង់ដីមួយកន្លែងទំហំ១៩៨១ម៉ែត្រក្រឡា ស្ថិតនៅភូមិ ៨ សង្កាត់ អូរគ្រែះ ខណ្ឌ ស្ទឹងហាវ ក្រុងព្រះសីហនុ មានទំហំ១៩៨១ម² និង មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ:ពន ០០៧៩៧៧ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៨ មកដាក់តម្កល់ជានា និង បានប្រគល់សិទ្ធិឲ្យឈ្មោះ [redacted] សុមាលា យកដីដាក់ធានានោះទៅលក់ដើម្បីយកប្រាក់មកទូទាត់ថែមទៀត ។ ដីដែលយកមកដាក់តម្កល់មានប័ណ្ណដូចខាងលើឈ្មោះ [redacted] ចាន់នី បានលក់ឲ្យអ្នកផ្សេងរួចហើយ កាលពីថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧ មិនមែនជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ចាន់នី ទៀតនោះទេ ។

តាមកំណត់ហេតុបណ្តឹងចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ របស់ឈ្មោះ [redacted] សុមាលា ប្តឹងឈ្មោះ [redacted] ចាន់នី ហៅ ប៊ី លីចាន់ ,ឈ្មោះ [redacted] សុវណ្ណវាសនា និង ឈ្មោះ [redacted] ស្រីម៉ាច ពីបទ: ឆបោកប្រាក់ចំនួន ៣៨១០០០ដុល្លាអាមេរិក ដោយសំអាងហេតុថា កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩ ឈ្មោះ [redacted] ចាន់នី បាននាំឈ្មោះ [redacted] សុវណ្ណវាសនា និង ប្រពន្ធឈ្មោះ ឡាយ ស្រីម៉ាច មកលក់ដីមួយកន្លែងមានទីតាំងស្ថិតនៅភូមិ ពូធឿង ឃុំ បិតត្រាង ស្រុក ព្រៃនប់ ខេត្ត ព្រះសីហនុ ក្នុងតម្លៃ ២០០០០០ ដុល្លាអាមេរិក ដោយមានកិច្ចសន្យា ហើយឈ្មោះ [redacted] ចាន់នី បានធ្វើលិខិតធានាមួយទៀតផងថា ដីដែលឈ្មោះ [redacted] សុវណ្ណវាសនា លក់ឲ្យខ្លួននេះពិតជាដីរបស់



Scanned with CamScanner

៧. ឈ្មោះ [redacted] សុមាលា សុំឲ្យបខ្លួនធ្វើជាសាក្សី ដោយផ្ដិតមេដៃលើកិច្ចសន្យាខ្ចីប្រាក់ និង លិខិតទទួលប្រាក់តាមការចង្អុលបង្ហាញកន្លែងឲ្យផ្ដិតមេដៃសាក្សីពីឈ្មោះ [redacted] ចាន់នី ។ ខ្លួនអត់បានមើលឯកសារទាំងពីរនេះទេ ហើយក៏មិនបានអានដែរ ពេលផ្ដិតរួចឈ្មោះ [redacted] ចាន់នី ហៅ ប៊ី លីចាន់ បានយកទៅវិញភ្លាម ហើយខ្លួនអត់បានឃើញអ្នកទាំងពីរប្រគល់ប្រាក់ទេ ខ្លួនសុំបដិសេធកិច្ចសន្យាខ្ចីប្រាក់ និង លិខិតទទួលប្រាក់ចុះថ្ងៃទី ១៥-៧-២០០៩ ចោលជាអសារបង់ កន្លងមកខ្លួនធ្លាប់បានទទួលប្រាក់ចំនួន១០០០០ដុល្លាអាមេរិក និង សែកមួយសន្លឹក មានដាក់ប្រាក់ចំនួន ១១០០០០ ដុល្លាអាមេរិក នៅថ្ងៃទី ២០-៦-២០០៩ ។ លុយនេះលុយខ្ចី ប៉ុន្តែធ្វើកិច្ចសន្យាទិញ-លក់ដីដោយរយៈពេលពីរខែក្រោយខ្លួនទិញយកដីនោះវិញ គឺក្នុងសំណុំរឿងផ្សេង ។ ខ្លួនអត់បានទទួលឯកសារចុះថ្ងៃទី ១៥-៧-២០០៩ ទាំងពីរច្បាប់នេះទេ សុំតុលាការលើកលែងចោទប្រកាន់ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ :៨៦(ជ) ចុះថ្ងៃទី ២២ ខែ ៥ ឆ្នាំ ២០១៣ របស់សាលាដំបូងរាជធានី ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

I/ ផ្តន្ទាទោស:

ក-ឈ្មោះ [redacted] ចាន់នី ហៅ ប៊ី លីចាន់ អាយុ ៥១ឆ្នាំ ជានជាតិខ្មែរ

ខ-ឈ្មោះ [redacted] សុវណ្ណវាសនា ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ

-ដាក់ពន្ធនាគារក្នុងម្នាក់ ៗ កំណត់ចំនួន ០១ឆ្នាំ០៦ខែ (មួយឆ្នាំប្រាំមួយខែ) និង ពិន័យជាប្រាក់ក្នុងម្នាក់ ៗ ចំនួន៤០០០០០០៛(បួនលានរៀល) ពីបទ: ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ និង មាត្រា ៣៧៨នៃក្រមព្រហ្មទណ្ឌ ។

II/ សាលក្រមនេះជំនុំជំរះនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៣ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុវណ្ណវាសនា កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ចាន់នី ហៅ ប៊ី លីចាន់ និង ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុមាលា ចាត់ទុកចំពោះមុខ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញរបាយការណ៍រឿងចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ របស់សាលាឧទ្ធរណ៍ ។

បានឃើញសេចក្តីសន្និដ្ឋានចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជំរះលេខ:០៩/១៤ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ របស់សាលាឧទ្ធរណ៍ ។

**ជាពេលសវនាការ**

ឈ្មោះ [redacted] ចាន់នី ហៅ ប៊ី លីចាន់ ជាជនជាប់ចោទ (អវត្តមាន)

ឈ្មោះ [redacted] សុមាលា ជាដើមបណ្តឹង (អវត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍រឿង

ឈ្មោះ [redacted] សុវណ្ណវាសនា ឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍មកនេះដើម្បីជួយរកយុត្តធម៌ពិតប្រាកដព្រោះថា លោក [redacted] ចាន់នី គាត់ធ្វើបែបនេះហើយម៉េចមិនជាប់ឃុំ ? ចំណុចអង្គហេតុដែលតុលាការផ្តន្ទាទោសខ្លួននេះ ខ្លួនមិនបានដឹងទេ ពីព្រោះពេលឈ្មោះ [redacted] ចាន់នី ទៅខ្ចីលុយពីឈ្មោះ [redacted] សុមាលា ខ្លួនមិនបានដឹងទេ លុះពេលគេពឹងមកឲ្យខ្លួនធ្វើជាសាក្សី ខ្លួនបានផ្តិតមេដៃ



Scanned with CamScanner

ក្នុងនាមជាសាក្សីប៉ុណ្ណោះ ពុំមានមេធាវីទេពេលផ្តិតមេដៃ ។ ខ្លួនមិនស្គាល់ដើមបណ្តឹងទេ ខ្លួនស្គាល់ឈ្មោះ [redacted]ណារិទ្ធ តាមការក្បែយធន០១៣ ហើយខ្លួន កន្លងមកបានទទួលលុយមានចំនួនដូចក្នុងរឿងមួយទៀត ចំពោះសាច់ប្រាក់ដប់ប្រាំបីម៉ឺននេះពិតជាអត់ដឹងមែន ខ្លួនហ៊ានស្បថគ្រប់ជាន់ថ្នាក់ ។ ខ្លួនជំបូងពិភាក្សាជាមួយឈ្មោះ [redacted]ណារិទ្ធ និង [redacted] ចាន់នី ដើម្បីខ្ចីប្រាក់យកទៅរត់ការ០១៣នេះ មិនបានសម្រេច ហើយក៏មានរឿងជាបន្តបន្ទាប់ ហើយមុននេះគាត់បានធ្វើរឿងមួយមានឡើងទៅសាលាដំបូងរាជធានីពីរឿងឡាន តែខ្លួនបាននាំអ្នកឃ្លាំង ឡានទៅជួបហើយរឿងនេះត្រូវបានបញ្ចប់ហើយ ត្រង់ផ្តិតមេដៃក៏ជាកំហុសឆ្គងរបស់ខ្លួនដែរ ដោយផ្តិតមេដៃមិនបានមើល ។ សំណូមពរតុលាការរកការពិត និង សម្រេចដោយយុត្តិធម៌ ព្រោះខ្លួនជាប់ ជាងពីរឆ្នាំហើយ ។

ក្រឡាបញ្ជីអានចម្លើយរបស់ឈ្មោះ [redacted]ចាន់នី ហៅ ប៊ី លីចាន់ ។

តំណាងមហាអយ្យការសន្និដ្ឋានថា ទាក់ទងនឹងអង្គហេតុនៃកិច្ចសន្យាឃើញថាការចោទប្រកាន់របស់តំណាងអយ្យការសាលាដំបូង និង ការសម្រេចសេចក្តីរបស់សាលាដំបូងរាជធានី ភ្នំពេញ ត្រឹមត្រូវហើយ គប្បីតម្កល់សាលក្រមនេះទុកជាបានការដដែល ។

លោកស្រី [redacted]នលាភី ថ្លែង និង សន្និដ្ឋានការពារដូចតទៅ: ក្នុងរឿងយកប្រាក់នោះគាត់មិនមែនជាសាក្សីទេ គឺជាអ្នកទទួលប្រាក់ទាំងពីរនាក់តែម្តង ហើយតាមការអានចម្លើយរបស់ឈ្មោះ [redacted] ចាន់នី នេះក៏គាត់ជាអ្នកទទួលប្រាក់ដែរ ។ កាលពីថ្ងៃទី ១៥ ខែ ៧ ឆ្នាំ ២០០៩ ឈ្មោះ [redacted]សុវណ្ណវាសនា និង ឈ្មោះ[redacted]ចាន់នី បានមករកកូនក្តីរបស់ខ្លួនខ្ចីប្រាក់ និងអះអាងថាមានដីដាក់បញ្ចាំ ទើបកូនក្តីខ្លួនព្រមឲ្យប្រាក់ទៅគាត់ខ្ចី ចំពោះការឆ្លើយរបស់ [redacted] សុវណ្ណ វាសនា ថាគាត់ជាសាក្សីលើការខ្ចីប្រាក់នេះឃើញថា ក្នុងកិច្ចសន្យាគឺគាត់ជាអ្នកផ្តិតមេដៃខ្ចីប្រាក់ លើក្រដាស០៦សន្លឹក និង មានប្រថាប់ត្រារបស់មេធាវីទៀតផង ។ ចំពោះឈ្មោះ[redacted]ចាន់នី ថា មានដីដាក់បញ្ចាំនឹងកូនក្តីខ្លួន តាមពិតដីនេះឈ្មោះអ្នកផ្សេងទេ ហើយនេះជាការបោកប្រាស់មកលើកូនក្តីខ្លួនទាំងស្រុង ក្នុងរឿងយកប្រាក់នោះគាត់មិនមែនជាសាក្សីទេ គឺជាអ្នកទទួលប្រាក់ទាំងពីរនាក់តែម្តងហើយតាមការអានចម្លើយរបស់ឈ្មោះ[redacted]ចាន់នី នេះក៏គាត់ជាអ្នកទទួលប្រាក់ដែរ ។

លោក [redacted]សុជល សន្និដ្ឋានការពារថា ឆ្លងតាមការឆ្លើយនាសវនាការកន្លងមកនេះ កូនក្តីខ្លួនបានបញ្ជាក់យ៉ាងច្បាស់លាស់ថា កូនក្តីខ្លួនមិនដែលខ្ចីលុយពីដើមបណ្តឹងទេ ហើយការផ្តិតមេដៃនោះត្រឹមជាសាក្សីប៉ុណ្ណោះ អ្នកខ្ចីលុយគឺឈ្មោះ [redacted] ចាន់នី បើពិនិត្យទៅលើអង្គហេតុនៃរឿងឃើញថា រឿងក្តីនេះជារឿងរដ្ឋប្បវេណីសុទ្ធសាធកើតចេញពីការខ្ចីប្រាក់ដាក់បញ្ចាំ ដូចនេះគួរតែជំរុញរឿងក្តីនេះទៅតុលាការរដ្ឋប្បវេណី សំណូមពរក្រុមប្រឹក្សាសម្រេចបដិសេធសាលក្រមព្រហ្មទណ្ឌលេខ: ៤៦"ជ" ចុះថ្ងៃទី ២២ ខែ ៥ ឆ្នាំ ២០១៣ របស់សាលាដំបូង ហើយសុំសម្រេចឲ្យកូនក្តីខ្លួនរួចពីបទចោទប្រកាន់ ។

លោក [redacted]ចំណាន សន្និដ្ឋានការពារថា ឆ្លងតាមការអានអង្គហេតុនៃរឿងឃើញថារឿងក្តីនេះជារឿងរដ្ឋប្បវេណីដែលកើតចេញពីការខ្ចីប្រាក់ ដូចនេះសូមក្រុមប្រឹក្សាពិចារណាទៅលើអង្គហេតុអំពីការខ្ចីប្រាក់របស់កូនក្តីខ្លួន បើសិនជាបោក យើងពិនិត្យទៅលើបណ្តឹងពាក់ព័ន្ធនឹងកិច្ចសន្យាខ្ចីប្រាក់នោះធ្វើចំពោះមុខមេធាវីថា កូនក្តីខ្លួនក្លែងឋានៈគឺក្លែងរបៀបម៉េច ចំពោះការឆ្លើយបែបនេះយើងមើលទៅលើមេធាវីដើមបណ្តឹង មិនមែនជាមេធាវីរបស់កូនក្តីខ្លួនសួថា មានការក្លែងឋានៈទេ បើប័ណ្ណកម្មសិទ្ធិបានផ្ទេរទៅឲ្យម្ចាស់មួយទៀតទៅហើយនោះ ដូចនេះដោយសារតែដើមបណ្តឹងចង់បានការប្រាក់ទើបបានទទួលយកប្លង់ដែលមិនមែនឈ្មោះកូនក្តីខ្លួននោះដាក់ឲ្យគាត់ កូនក្តីខ្លួន



Scanned with CamScanner

លួងលោម ឬ កុហកឲ្យផ្តិតមេដៃទើបដឹងថា ឆបោក បាន ។ ជារួមអង្គហេតុនេះជារឿងរដ្ឋប្បវេណី ហើយ មានសាលក្រមរឿងមួយទៀតបានបង្ហាញថា រឿងនេះជារឿងរដ្ឋប្បវេណីដែរ ព្រោះថាសាលក្រមនេះលេខៈ ០៨ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ បានបង្ហាញច្បាស់លាស់រួចទៅហើយ មានទាំងការលក់ឡាយឡុងទាំងបង្ខំទៀតផង ។ ដូចនេះក្នុងរឿងនេះពុំមានការក្លែងឋានៈលួងលោមក្លែងបន្លំទេ គឺរឿនេះមានកិច្ចសន្យាគ្រប់គ្រាន់ដែលពុំបានកើតពីការឆបោក ជារឿងព្រហ្មទណ្ឌឡើយ សំណូមពរបដិសេធសាលក្រមលេខៈ ៩៦"ជ" ចុះថ្ងៃទី ២២ ខែ ៥ ឆ្នាំ ២០១៣ របស់សាលាដំបូងចោលជាអសារបង់ និង សុំឲ្យកូនក្តីរួចពីបទចោទប្រកាន់ ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឆ្លើយ និង ប្តឹងសុំ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឲ្យដើមបណ្តឹងឆ្លើយ និង ប្តឹងសុំ ។

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីរបស់ជនជាប់ចោទឆ្លើយ និង ប្តឹងសុំ

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាឧទ្ធរណ៍-យល់ឃើញថា**

១. បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៩ ខែ ៥ ឆ្នាំ ២០១៣ របស់ឈ្មោះ [redacted] សុវណ្ណវាសនា និង បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ៣០ ខែ ៥ ឆ្នាំ ២០១៣ របស់លោកមេធាវី [redacted] ចំណាន ធ្វើឡើងត្រឹមត្រូវក្នុងកំណត់ច្បាប់សាលាឧទ្ធរណ៍ទទួលជំនុំជំរះបានយោងមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណវាសនា បានបញ្ជាក់ថា ចំណុចអង្គហេតុដែលតុលាការផ្តន្ទាទោសខ្លួននេះ ខ្លួនមិនបានដឹងទេ ពីព្រោះពេលឈ្មោះ [redacted] ចាន់នី ទៅខ្ចីលុយពី ឈ្មោះ [redacted] សុមាលា ខ្លួនមិនបានដឹងទេ លុះពេលគេពឹងមកឲ្យខ្លួនធ្វើជាសាក្សី ខ្លួនបានផ្តិតមេដៃក្នុងនាមជាសាក្សីប៉ុណ្ណោះ ពុំមានមេធាវីទេពេលផ្តិតមេដៃ ។ ខ្លួនមិនស្គាល់ដើមបណ្តឹងទេ ខ្លួនស្គាល់ឈ្មោះ [redacted] ណារិទ្ធ តាមការក្បៀយធន០១៣ ហើយខ្លួនកន្លងមកបានទទួលលុយមានចំនួនដូចក្នុងរឿងមួយទៀត ចំពោះសាច់ប្រាក់ដប់ប្រាំបីម៉ឺននេះពិតជាអត់ដឹងមែន ខ្លួនហ៊ានស្បថគ្រប់ជាន់ថ្នាក់ ។ សំណូមពរតុលាការរកការពិត និង សម្រេចដោយយុត្តិធម៌ ព្រោះខ្លួនជាប់ជាងពីរឆ្នាំហើយ ។

៣. តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់នី បានបញ្ជាក់ថា កាលដែលខ្លួនផ្តិតមេដៃចុះថ្ងៃទី ១៥-៧-២០០៩ ដែលមានទឹកប្រាក់ចំនួន ១៥៦០០០ដុល្លា និង កិច្ចសន្យា ខ្ចីប្រាក់ចុះថ្ងៃទី ១៥-៧-២០០៩ មានទឹកប្រាក់២៥០០០ដុល្លា សរុបចំនួន១៨១០០០ដុល្លានេះ ខ្លួនផ្តិតមេដៃតាមការអូសទាញបញ្ចុះបញ្ចូលរបស់ឈ្មោះ [redacted] ណារិទ្ធ និង ឈ្មោះ [redacted] សុមាលា តាមខ្លួនដឹងឈ្មោះ [redacted] សុវណ្ណវាសនា បានទទួលប្រាក់តែចំនួនមួយភាគបី(១/៣) ចំនួនប្រាក់សរុបប៉ុណ្ណោះ ។ ក្នុងរឿងកិច្ចសន្យានេះឈ្មោះ [redacted] សុមាលា បានដាក់បណ្តឹងរក្សាការពារនៅខេត្ត ព្រះសីហនុ ហើយតុលាការបានចេញដីកាសម្រេចរក្សាការពារឃាត់ទ្រព្យសម្បត្តិរបស់ខ្លួនរួចហើយ ។ [redacted] សុមាលា បានដាក់ពាក្យបណ្តឹងមកសាលាដំបូងរាជធានី ភ្នំពេញ ដែលតុលាការរដ្ឋប្បវេណីកំពុងចាត់ការ ។ ក្នុងរឿងនេះខ្លួនអត់បានទទួលប្រាក់ពីឈ្មោះ [redacted] សុមាលា ទេ ហើយការផ្តិតមេដៃនេះ មិនធ្វើចំពោះមុខមេធាវីទេ ហើយក៏អត់ទទួលកិច្ចសន្យាដែរ គឺឈ្មោះ [redacted] សុវណ្ណវាសនា ជាអ្នកទទួល និង រក្សាទុក ព្រោះ [redacted] សុវណ្ណវាសនា ជាអ្នកយកលុយទៅរត់ការបន្តតាមការពឹងរបស់



Scanned with CamScanner

ឈ្មោះ [redacted] ណារិទ្ធ ។ សំណូមពរតុលាការកុំឃុំខ្លួន និង សុំ លើកលែងចោទប្រកាន់ព្រោះរឿងនេះ តុលាការរដ្ឋប្បវេណីកំពុងចាត់ការ ។

៤. តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុមាលា បាន បញ្ជាក់ថា កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩ ឈ្មោះ គឹម ចាន់នី បាននាំឈ្មោះ [redacted] សុវណ្ណ វាសនា និង ប្រពន្ធឈ្មោះ [redacted] ស្រីម៉ាច មកលក់ដីមួយកន្លែងមានទីតាំងស្ថិតនៅភូមិ ព្រជៀង ឃុំ បិតត្រាង ស្រុក ព្រៃនប់ ខេត្ត ព្រះសីហនុ ក្នុងតម្លៃ ២០០០០០ ដុល្លាអាមេរិក ដោយមានកិច្ចសន្យា ហើយឈ្មោះ [redacted] ចាន់នី បានធ្វើលិខិតធានាមួយទៀតផងថា ដីដែលឈ្មោះ [redacted] សុវណ្ណវាសនា លក់ឲ្យខ្លួននេះពិតជាដីរបស់ [redacted] សុវណ្ណវាសនា ។ បន្ទាប់មកនៅថ្ងៃទី ១៥-កក្កដា-២០០៩ ឈ្មោះ [redacted] ចាន់នី និង ឈ្មោះ [redacted] សុវណ្ណវាសនា បានមកខ្ចីប្រាក់ពីខ្លួនចំនួន ១៨១០០០ដុល្លាអាមេរិក ដោយយកប្លង់ដីមួយកន្លែង មានទីតាំងនៅភូមិ ៤ សង្កាត់ អូរគ្រះ ខណ្ឌ ស្ទឹងហាវ ក្រុងព្រះសីហនុ មាន ទំហំ១៩៨១ម² និង មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខៈ៣ន ០០៧៩៧៧មកដាក់ បញ្ចាំ ក្រោយពីអ្នកទាំងបីទទួលប្រាក់ពីខ្លួនសរុប ៣៨១០០០ដុល្លាអាមេរិកគឺអ្នកទាំងបីមិនចាត់ផ្ទេរ កម្មសិទ្ធិ កាន់កាប់ដីឲ្យខ្លួនឡើយ ។ ដោយមានការសង្ស័យខ្លួនទៅសួរបញ្ជាក់ម្តងទៀតនៅភូមិ-ឃុំ ទើបបានដឹងថា ដីដែល ឈ្មោះ [redacted] សុវណ្ណវាសនា ទៅលក់ឲ្យខ្លួននោះគឺមិនមែនជាដីកម្មសិទ្ធិរបស់ ខ្លួនទេ ចំណែកដីដែល ឈ្មោះ [redacted] ចាន់នី បានមកដាក់បញ្ចាំខ្លួននោះគឺជាដីរបស់ឈ្មោះ ស៊ុក ឌី ដែលបានទិញពីឈ្មោះ [redacted] ចាន់នី តាំងពីថ្ងៃទី ០១-វិច្ឆិកា-២០០៧ ម្លេះ ។ សំណូមពរផ្តន្ទាទោស ជនល្មើសតាមច្បាប់ និង ទាមទារសងប្រាក់មកខ្លួនចំនួន ៣៨១០០០ដុល្លាអាមេរិក ជម្ងឺចិត្ត ១០០០០០ដុល្លាអាមេរិក ។

៥. តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា តម្កល់សាលក្រមព្រហ្ម ទណ្ឌលេខៈ ៤៧(ខ) ចុះថ្ងៃទី ១៤ ខែ ៨ ឆ្នាំ ២០១៣ របស់សាលាដំបូងរាជធានី ភ្នំពេញ ទុកជាបាន ការដដែល។

៦. មេធាវីការពារឲ្យឈ្មោះ [redacted] សុវណ្ណវាសនា បានធ្វើសេចក្តីសន្និដ្ឋានបញ្ជាក់ថា កូនក្តីខ្លួនបានបញ្ជាក់យ៉ាងច្បាស់លាស់ថា កូនក្តីខ្លួនមិនដែលខ្ចីលុយពីដើមបណ្តឹងទេ ហើយ ការ ផ្តិតមេដៃនោះត្រឹមជាសាក្សីប៉ុណ្ណោះ អ្នកខ្ចីលុយគឺឈ្មោះ [redacted] ចាន់នី បើពិនិត្យទៅលើអង្គហេតុនៃ រឿងឃើញថា រឿងក្តីនេះជារឿងរដ្ឋប្បវេណីសុទ្ធសាធកើតចេញពីការខ្ចីប្រាក់ដាក់បញ្ចាំ ដូចនេះគួរ តែជំរុញរឿងក្តីនេះទៅតុលាការរដ្ឋប្បវេណី សំណូមពរក្រុមប្រឹក្សាសម្រេចបដិសេធសាលក្រម ព្រហ្មទណ្ឌលេខៈ ៤៦"ជ" ចុះថ្ងៃទី ២២ ខែ ៥ ឆ្នាំ ២០១៣ របស់សាលាដំបូង ហើយសុំសម្រេច ឲ្យកូនក្តីខ្លួនរួចពីបទចោទប្រកាន់ ។

៧. មេធាវីការពារឲ្យឈ្មោះ [redacted] ចាន់នី បានធ្វើសេចក្តីសន្និដ្ឋានបញ្ជាក់ថា រឿងក្តី នេះជារឿងរដ្ឋប្បវេណី ដែលកើតចេញពីការខ្ចីប្រាក់ ដូចនេះសូមក្រុមប្រឹក្សាពិចារណាទៅលើអង្គ ហេតុអំពីការខ្ចីប្រាក់របស់កូនក្តីខ្លួន បើសិនឆបោក យើងពិនិត្យទៅលើបណ្តឹងពាក់ព័ន្ធនឹងកិច្ចសន្យា ខ្ចីប្រាក់នោះធ្វើចំពោះមុខមេធាវីថា កូនក្តីខ្លួនក្លែងបន្លំគឺក្លែងរបៀបម៉េច ចំពោះការឆ្លើយបែបនេះ យើងមើលទៅលើមេធាវីដើមបណ្តឹងមិនមែនជាមេធាវីរបស់កូនក្តីខ្លួន សួរថា មានការក្លែងបន្លំទេ បើប័ណ្ណកម្មសិទ្ធិបានផ្ទេរទៅឲ្យម្ចាស់មួយទៀតទៅហើយនោះ ដូចនេះដោយសារតែដើមបណ្តឹងចង់ បានការប្រាក់ទើបបានទទួលយកប្លង់ដែលមិនមែនឈ្មោះកូនក្តីខ្លួននោះដាក់ឲ្យគាត់ ។ ដូចនេះក្នុង រឿងនេះពុំមានការក្លែងបន្លំ លួងលោម ក្លែងបន្លំទេ គឺរឿងនេះមានកិច្ចសន្យាគ្រប់គ្រាន់ដែលពុំបាន



Scanned with CamScanner

កើតពីការឆបោកជារឿងព្រហ្មទណ្ឌឡើយ សំណូមពរបដិសេធសាលក្រមលេខ:៨៦"ជ ខែ ៥ ឆ្នាំ ២០១៣ របស់ សាលាដំបូងចោលជាអសារបង់ និង សុំឲ្យកូនក្តីរួចពីបទចោទប្រកាន់ ។

៨. ជនជាប់ចោទឈ្មោះ [redacted] ចាន់នី ដែលមានឈ្មោះ [redacted] សុវណ្ណវាសនា បានចូលរួមដៃរនោះ បានយកប្លង់លេខ:ពន០០៧៩៧៧ ចុះថ្ងៃទី ០៤-០១-២០០៨ មកដាក់បញ្ចាំឲ្យជនរងគ្រោះដើម្បីខ្ចីប្រាក់ចំនួន១៨១០០០ដុល្លា ។ ប៉ុន្តែតាមពិតអចលនវត្ថុខាងលើ ឈ្មោះ [redacted] ចាន់នី បានលក់ឲ្យអ្នកដទៃតាំងពីថ្ងៃទី ០៦-១១-២០០៧ រួចហើយ ។

៩. មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] សុវណ្ណវាសនា ពីបទ: ឆបោក ប្រព្រឹត្តរាជធានី ភ្នំពេញ កាលពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩ តាមបញ្ញត្តិមាត្រា ៣៧៧ និង មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

១០. ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណវាសនា បានធ្វើសំណូមពរចុងក្រោយថា សំណូមពរតុលាការរកការពិត និង សម្រេចដោយយុត្តិធម៌ ព្រោះខ្លួនជាប់ជាងពីរឆ្នាំហើយ ។

១១. រឿងក្តីនេះត្រូវបានសាលាដំបូងរាជធានី ភ្នំពេញ ធ្វើការអង្កេត និង លើកយកសំអាងហេតុមកបញ្ជាក់ត្រឹមត្រូវហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដូចនេះ សាលាឧទ្ធរណ៍មិនចាំបាច់លើកសំអាងហេតុនេះមកបញ្ជាក់សាជាថ្មីទៀតទេ ។

១២. សាលក្រមព្រហ្មទណ្ឌលេខ: ៨៦(ជ) ចុះថ្ងៃទី ២២ ខែ ៥ ឆ្នាំ ២០១៣ របស់ សាលាដំបូងរាជធានី ភ្នំពេញ សម្រេចមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និង គតិច្បាប់ហើយ គប្បីតម្កល់ទុកជាបានការតទៅ ។

## ហេតុដូច្នេះ-វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៩ ខែ ៥ ឆ្នាំ ២០១៣ របស់ឈ្មោះ [redacted] សុវណ្ណវាសនា និង បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ៣០ ខែ ៥ ឆ្នាំ ២០១៣ របស់លោក [redacted] ចំណាន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ : ៨៦(ជ) ចុះថ្ងៃទី ២២ ខែ ៥ ឆ្នាំ ២០១៣ របស់សាលាដំបូងរាជធានី ភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣. បន្តការឃុំខ្លួនឈ្មោះ [redacted] សុវណ្ណវាសនា ។

៤. សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៤ ចំពោះមុខជនជាប់ចោទ និង មេធាវីដើមបណ្តឹង។

- បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

*សេចក្តីនេះព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាសបង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់ដំណែង និង កងកម្លាំងប្រដាប់អាវុធជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាម ច្បាប់ហើយ ។*

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
| --- | --- | --- |
| ហត្ថលេខា [redacted] | ហត្ថលេខា : [redacted] | ហត្ថលេខា : [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០១៤
ក្រឡាបញ្ជី

[redacted]

២៩៨



Scanned with CamScanner